ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និង ឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០

**សេចក្តីសំរេចលេខ ៣៥ សសរ**

**ស្តីពីការប្រគល់ភារកិច្ចជូនទីប្រឹក្សា**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៩៥ ចុះថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការតែងតាំងទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- **យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការអចិន្ត្រៃយ៍**

**សំរេច**

**ប្រការ ១ :** ប្រគល់ភារកិច្ចជូនឯកឧត្តមឧត្តមសេនីយ៍ទោ ម៉ែន ស៊ិន ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រីអោយទទួលតាមដាន និងក្តាប់សភាពការណ៍រួម ពិសេសសភាពការណ៍នៃគ្រោះមហន្តរាយនានានៅក្នុងខេត្តព្រៃវែង និងកំពង់ចាម ។

**ប្រការ ២ :** ឯកឧត្តម ម៉ែន ស៊ិន មានសិទ្ធិចូលរួមគ្រប់ពេលប្រជុំរបស់ថ្នាក់ដឹកនាំខេត្ត និងស្នងការដ្ឋាននគរបាលខេត្តទាំង ២ ដើម្បីរួមយោបល់លើបញ្ហាផ្សេងៗរបស់ខេត្ត ឬ ស្នងការដ្ឋាននគរបាល ខេត្ត ។

-ឯកឧត្តម ម៉ែន ស៊ិន មានសិទ្ធិជ្រើសរើសមន្ត្រីពី១ ទៅ ២នាក់ ដែលមានក្របខ័ណ្ឌស្រាប់ ជាជំនួយការ ។

-ឯកឧត្តម ម៉ែន ស៊ិន ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងារដែលសំរេចបានផ្ញើជូនឧបនាយករដ្ឋមន្ត្រី ស ខេង តាមរយៈខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាល ខេត្ត ក្រុង ស្នងការនគរបាលខេត្តទាំង ២ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

### និស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០០

### ប្រកាស

### ប្រកាសលេខ ១៩៨/០០ ពម.ប្រក

### ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន
- យោងលិខិតលេខ ៦២ មស.ពក ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០០ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការឯកភាពចំពោះសំណើសុំតែងតាំងលោក សំបូរ ទណ្ឌារិទ្ធ ជាអនុប្រធាននាយកដ្ឋាន
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ